# ការសំភាសន៍របស់អ៊ុំ ហឹម ហេន

**កៈ អ្នកសំភាសន៍ឈ្មោះ ជាង ស៊ីអ៊ាង        ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ហឹម ហេន**

## ការសង្ខេបប្រវត្តិរបស់អ៊ុំ ហឹម ហេន

អ៊ុំ ហឹម ហេន មានអាយុ ៨៤ ឆ្នាំ នៅក្នុងឆ្នាំ ២០១៨។ អ៊ុំ ហឹម ហេន មានភេទប្រុស។ អ៊ុំ ហឹម ហេន មានទីលំនៅបច្ចុប្បន្ននៅភូមិទី៦ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

ខៈ អស័យដ្ឋាននៅសព្វថ្ងៃនេះហោស?

កៈ បាទដូចជានៅនឹងហាសអ៊ុំ?

ខៈ អស័យដ្ឋានសព្វថ្ងៃនឹងអ៊ុំដាក់តែអស័យដ្ឋានស្ថានីយ៍បូមទឹក

កៈ នៅស្ថានីយ៍បូមទឹក ប៉ុន្តែភូមិអី ឃុំអីអ៊ុំមានដឹងទេអ៊ុំ?

ខៈ នឹងពេលដែរបច្ចុប្បន្ននឹងហោស?

កៈ បាទអ៊ុំនៅពេលបច្ចុប្បន្ននឹងអ៊ុំ?

ខៈ នៅភូមិ ៦ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅក្រុងភ្នំពេញ?

កៈ មិនមែនខ័ណ្ឌមានជ័យទេហោសអ៊ុំ?

ខៈ នឹងអ៊ុំដាក់ការនៅពីមុន តែឥឡូវនឹងអ៊ុំមកជួលផ្ទះគេចឹងអ៊ុំអត់ដាក់ទេ

កៈ ចឹងអ៊ុំនៅភូមិ ៦ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ បាទយល់ព្រមតា

កៈ ចុះសំរាប់ឈ្មោះពេញរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ឈ្មោះពេញរបស់ខ្ញុំនឹងឈ្មោះ ហឹម ហេននឹងតែម្តងនឹង

កៈ ចឹងដូចជាមានឈ្មោះហៅក្រៅអីទេអ៊ុំ?

ខៈ អត់មានទេ

កៈ ចឹងអត់មានទេហោសអ៊ុំ?

ខៈ មានឈ្មោះតែមួយគត់នឹង

កៈ ចឹងតាំងពីក្មេងរហូតមកដល់ឥឡូវនឹងមានឈ្មោះតែមួយនឹងទេណាអ៊ុំ?

ខៈ មានឈ្មោះតែមួយនឹង

កៈ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរហើយអ៊ុំ?

ខៈ សព្វថ្ងៃនឹងបើមើលតាមអត្តសញ្ញាណប័ណនឹងគឺអាយុ៨៥ឆ្នាំ

កៈ ចុះអ៊ុំមានចងចាំថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំអត់ទេអ៊ុំ?

ខៈ ខ្ញុំចាំតា កើតនៅថ្ងៃទី១០ ខែ១០ នៅឆ្នាំ១៩៣៣ នឹងដាក់តាមអត្តសញ្ញាណប័ណនឹងហាស

កៈ បាទអ៊ុំចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ អ៊ុំកើតនៅភូមិគោករកា ឃុំរាមអណ្តើក ស្រុកគិរីវង្ស ខេត្តតាកែវ

កៈ អូ៎!នៅខេត្តតាកែវហោសអ៊ុំ ចុះសំរាប់ឆ្នាំខ្មែរអ៊ុំមានចងចាំអត់ ឆ្នាំច័ន្ទគតិហាស
អ៊ុំមានចងចាំថាអ៊ុំកើតនៅឆ្នាំអីគេដែរទេ លក្ខណៈថាឆ្នាំជូត ឆ្លូវអីហាស?

ខៈ បើតាមអត្តសញ្ញាណប័ណនេះយើងឆ្នាំច

កៈ អូ៎!នៅឆ្នាំច ហោសអ៊ុំ ចុះអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនតែ២នាក់ទេ

ក៖  អូ!មានតែ២នាក់ទេ ចុះអ៊ុំជាកូនបងរឺមួយក៏កូនប្អូនដែរអ៊ុំ?

ខ៖  អ៊ុំជាកូនប្អូន

ក៖  អូ!កូនពៅហោសអ៊ុំ?

ខ៖  បាទកូនប្អូន ហើយប្រុសទាំងពីរនាក់នឹង

ក៖  ចុះបងរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  បងប្រុសគាត់មានឈ្មោះណូ ហាន

ក៖  ឈ្មោះណូ ហាន ហោសអ៊ុំ?

ខ៖  គាត់ដាក់ជីតា ហើយខ្ញុំដាក់ ហ៊ឹម ហេន

ក៖  អូ!ផ្សេងគ្នា ចុះអ៊ុំធ្លាប់មានសាច់រឿងអីជាមួយគាត់ដែរទេ ជាមួយបងប្រុសរបស់អ៊ុំហាស លក្ខណះសាច់រឿងអីដែរសប្បាយការជាមួយគ្នាដែរចឹងហាស?

ខ៖  អ៊ុំមានការសប្បាយច្រើនពីព្រោះបងរបស់អ៊ុំគាត់បានស្រលាញ់អ៊ុំណាស់ ពីព្រោះធ្វើតាមណ្តាំរបស់ឪពុកចឹងហាស

ក៖  ឪពុករបស់អ៊ុំគាត់ថាម៉េចទៅ?

ខ៖  គាត់ថាបងប្អូនត្រូវចេះស្រលាញ់គ្នា លក្ខណះជួយឃិតយូងគ្នាអោយបានរីកចំរើន ទាំងខាងវិញ្ញាណនឹងទាំងខាងសាច់ឈាម ឪពុករបស់អ៊ុំគាត់ផ្តាំមកចឹង

ក៖  អូ!ឪពុករបស់អ៊ុំគាត់និយាយចឹង?

ខ៖  គាត់ថាបើសិនជាឃើញប្អូនមិនល្អគាត់ទាញអោយធ្វើល្អឡើង

ក៖  ចឹងហោសអ៊ុំ?

ខ៖  បាទហើយកាលណោះខ្ញុំនៅផ្ទះ នឹកឃើញថាប្អូនមិនទាន់ចេះអក្សរអីចឹង ខ្ញុំរៀនបានតែ៨ ខែទេ គ្រាន់តែមើលបាន ហើយសរសេរបាន គាត់មិននិយាយច្រើនគាត់ក៏នាំអ៊ុំទៅបួស

កៈ អូ៎!អ៊ុំទៅបួសធ្វើជាលោក?

ខៈ នឹងហើយគាត់ទៅបួសហោស
ហើយអ៊ុំទៅបួសជាមួយគាត់ហើយអ៊ុំទៅរៀនព្រះត្រៃបិដក់ គិតទៅទៅបួសអស់៧ឆ្នាំ
ទៅរៀនព្រោះត្រៃបិដក់នឹងរហូត លក្ខណៈថាស្រលាញ់គ្នាណាស់

កៈ ចុះកាលពីអ៊ុំនៅក្មេងហាស តើអ៊ុំចូលចិត្តធ្វើអីជាមួយបងរបស់អ៊ុំដែរ
ដូចលក្ខណៈថាលេងឡើកបាយឡ រឺក៏លេងល្បែងអីចឹង រឺក៏ដើរលេងអីជាមួយគ្នាចឹងហាសអ៊ុំ?

ខៈ ធម្មតាទេ ពីព្រោះកាលណោះអ៊ុំនៅស្រុកស្រែ
កាលលេងសប្បាយជាមួយគាត់មិនដែរតាស់គ្នាទេ ហើយលេងបិទពួនអី
លក្ខណៈលេងល្បែងយើងពីដើមនឹង មានតែប៉ុណ្ណឹងទេដៃរលេងជាមួយគ្នានឹងហាស

កៈ អ៊ុំចេះស្រលាញ់គ្នានឹង?

ខៈ សំខាន់បំផុត ខ្ញុំទៅឃ្វាលគោ ពេលទៅឃ្វាលគោនឹង ឪពុកគាត់មានគោទាំងអស់មាន៦
ទៅ៧នឹង ហើយគាត់ដឹកគោ៤ ហើយខ្ញុំដឹកគោ៣ ដឹកគោអោយទៅស៊ីស្មៅ

កៈ លក្ខណៈថាដឹកទៅស៊ីស្មៅមែនអ៊ុំ?

ខៈ ដឹកទៅស្រែនឹង ហើយលែងវាអោយស៊ីស្មៅនឹង

កៈ ចុះអ៊ុំគិតថាបងរបស់អ៊ុំនឹងគាត់រស់នៅណាដែរ ហើយគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ គាត់ស្លាប់បាត់ហើយនឹង

កៈ អូ៎!គាត់ស្លាប់បាត់ហើយហោសអ៊ុំ?

ខៈ បាទ! គាត់ធ្វើជាគ្រូបង្រៀននៅឯខេត្តតាកែវហោស

កៈ ប៉ុន្តែគាត់ស្លាប់យូរដែរហើយណអ៊ុំ?

ខៈ គាត់ស្លាប់យូរឆ្នាំដែរហើយនឹង

កៈ ចឹងគាត់ស្លាប់យូរដែរហើយ?

ខ៖ គាត់ស្លាប់សឹងតែ១៥ឆ្នាំហើយនឹង

ក៖ ប៉ុន្តែបងរបស់អ៊ុំនឹងត្រូវជាបងរបស់អ៊ុំប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖ គាត់បងខ្ញុំ៥ឆ្នាំ

ក៖ អូ្៎!គាត់បងអ៊ុំ៥ឆ្នាំ ចឹងបើដល់ឥឡូវនឹងគាត់ប្រហែលជា៩០ឆ្នាំហើយណាអ៊ុំ?

ខ៖ នឹងហើយប្រហែលប៉ុណ្ណឹង មើលគាត់ស្លាប់តាំងពីអាយុ៧២ឆ្នាំ ចឹងប្រហែលជា១៤-១៥ឆ្នាំហើយខ្ញុំមិនដែរបានគិតគូផងនឹង

ក៖ ចឹងអ៊ុំអាយុ៨៤ឆ្នាំ ចឹងវា៥ឆ្នាំ ចឹងវាអាចនឹង៨៩ឆ្នាំ?

ខ៖ នឹងហើយប៉ុណ្ណឹង

ក៖ ចឹងបងប្រុសរបស់អ៊ុំប្រហែលជាអាយុ៩០ឆ្នាំនឹង?

ខ៖ អើរប៉ុណ្ណឹងហើយនឹង បើគាត់មិនទាន់ស្លាប់នៅប្រហែលប៉ុណ្ណឹងមែនទេ?

ក៖ បាទប៉ុណ្ណឹងអ៊ុំ ចុះម្តាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានឈ្មោះ សុភី

ក៖ ម្តាយឈ្មោះ សុភី ចុះឪពុកវិញអ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឪពុកមានឈ្មោះ ណូ ហឹម

ក៖ ចុះម្តាយរបស់អ៊ុំគាត់មានអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ បើគិតទៅគាត់ប្រហែលជាអាយុមួយរយជាងហើយនឹង គាត់កើតនៅឆ្នាំ១៩០៤អីនឹង

ក៖ គាត់កើតនៅឆ្នាំ១៩០៤ហោសអ៊ុំ?

ខ៖ បាទពេលដែរខ្ញុំធ្វើប្រវត្តិរូបទៅព្រះវិហារបរិសុទ្ធនោះ

ក៖ ចុះឪពុករបស់អ៊ុំគាត់ប្រហែលជាអាយុប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖  ឪពុកនឹងគាត់បងម្ដាយរបស់ខ្ញុំប្រហែលជា៥ឆ្នាំនឹង គាត់ស្លាប់អស់ហើយនឹង

ក៖  ប៉ុន្តែអ៊ុំមានដឹងថាម្ដាយរបស់អ៊ុំនឹងគាត់កើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖  កាលណុងខ្ញុំដាក់ឪពុកគាត់កើតនៅឆ្នាំ១៩០០ ហើយម៉ាក់នឹងគាត់ឆ្នាំ១៩០៤ គាត់បងប្អូនគ្នា៤ឆ្នាំនឹងហាស

ក៖  ចឹងមានន័យថាឪពុករបស់អ៊ុំកើតនៅឆ្នាំ១៩០០ ហើយម្ដាយរបស់អ៊ុំគាត់កើតឆ្នាំ១៩០៤ ណាអ៊ុំ?

ខ៖  បាទៗៗនឹងហើយ

ក៖  ប៉ុន្តែអ៊ុំមានដឹងថាគាត់ឆ្នាំច័ន្ទគតិគាត់ឆ្នាំអីដែរទេអ៊ុំ លក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំ?

ខ៖  ប៉ារបស់ខ្ញុំគាត់កើតឆ្នាំជូត

ក៖  គាត់ឆ្នាំជូត ចុះម្ដាយរបស់អ៊ុំវិញឆ្នាំអីគេដែរអ៊ុំ?

ខ៖  ម៉ាក់របស់ខ្ញុំគាត់កើតឆ្នាំខាល

ក៖  អូ៎!ម្ដាយរបស់អ៊ុំគាត់ឆ្នាំខាលណាអ៊ុំ ចុះអ៊ុំមានដឹងថាម្ដាយរបស់អ៊ុំគាត់កើតនៅណាដែរទេអ៊ុំ?

ខ៖  ម្ដាយរបស់អ៊ុំគាត់កើតនៅភូមិកំណើត អ៊ុំនិយាយមិញនឹងនៅភូមិគោករកា ឃុំគោកអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ

ក៖  បាទអ៊ុំ ចុះឪពុករបស់អ៊ុំវិញគាត់កើតនៅណាដែរអ៊ុំ?

ខ៖  ឪពុករបស់អ៊ុំគាត់កើតនៅជាមួយគ្នានឹង

ក៖  អូ៎!គាត់នៅភូមិជាមួយគ្នានឹងហោសអ៊ុំ?

ខ៖  នឹងហើយនៅភូមិជាមួយគ្នានឹង

ក៖  ចុះឪពុករបស់អ៊ុំគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ កាលមុនគាត់ជាកសិករហាស ប៉ុន្តែពីមុនគាត់ជាកសិករ កាលជំនាន់បារាំងគាត់ធ្វើជាគ្រូបង្រៀនដែរនឹង

ក៖ អូ!ពីមុនគាត់ជាគ្រូបង្រៀនហោសអ៊ុំ?

ខ៖ គាត់ជាគ្រូបង្រៀនតាមសាលាវត្តនឹង កាលណុងប្រាក់ខែលឺថា៤កាក់

ក៖ អូ!ប្រាក់ខែ៤កាក់ហោសអ៊ុំ?

ខ៖ នឹងហើយគាត់មានជាសៀវភៅអោយអ៊ុំរៀនរហូតដល់អ៊ុំធំមក ឃើញមានលេខបូក លេខដកអីនឹងហាស

ក៖ អូ!ចឹងហោសអ៊ុំ?

ខ៖ បាទឃើញគាត់មានចឹងមានន័យថាគាត់ជាគ្រូបង្រៀនដែរនឹងហាស ហើយម៉ែគាត់ដកស្ទូងទៅ គាត់ជាកសិករនឹង

ក៖ ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំជាមេផ្ទះ នឹងគាត់ធ្វើស្រែ

ក៖ ចឹងម្តាយរបស់អ៊ុំគាត់ធ្វើតែប៉ុណ្ណឹងទេណាអ៊ុំ គាត់អត់មានធ្វើអីទៀតទេណាអ៊ុំ?

ខ៖ អត់ទេគាត់ធ្វើតែស្រែទេនឹង ហើយនឹងគាត់ជាអ្នកត្បាញហូល

ក៖ អ៎!គាត់ត្បាញហូលដែរហោសអ៊ុំ?

ខ៖ នឹងហើយគាត់ត្បាញហូលនឹងដែរ ហើយគាត់ត្បាញក្រម៉ា ហើយគាត់ត្បាញហូលស្អាតណាស់

ក៖ អូ!គាត់ពូកែត្បាញណាអ៊ុំ?

ខ៖ នឹងហើយគាត់ត្បាញហូលលក្ខណះថាដូចគ្របសៀវភៅមរមនអីចឹងហាសណាស់ មានរូបដំរី នឹងរូបអីចឹង

ក៖ ចឹងឪពុករបស់អ៊ុំគាត់ធ្វើតែគ្រូនឹងធ្វើអីតែប៉ុណ្ណឹងទេណាអ៊ុំ?

ខ៖  បាទធ្វើតែប៉ុណ្ណឹង គាត់ធ្វើតែគ្រូ នឹងធ្វើស្រែនឹង

ក៖  នឹងសំរាប់ចិញ្ចឹមកូន នឹងចិញ្ចឹមក្រុមគ្រួសារ?

ខ៖  នឹងហើយសំរាប់ចិញ្ចឹមគ្រួសារ

ក៖  ចុះឪពុករបស់អ៊ុំគាត់លក្ខណៈថាគាត់ស្លូត រឺមួយក៏កាចនៅក្នុងក្រុមគ្រួសារងឺចឹងហាសអ៊ុំ?

ខ៖  គាត់ស្លូតបូត មានគេរាប់អានគាត់ច្រើនគេមិនសូវនិយាយស្ដីអីច្រើនទេ

ក៖  អូ្ហ!ចឹងគាត់មិនសូវចេះនិយាយស្ដីទេ?

ខ៖  នឹងហើយគាត់និយាយសាច់ការហាស
បើគាត់និយាយស្ដីជាមួយបងប្អូនអីនឹងលក្ខណៈថាសមញ្ញនឹងដែរ

ក៖  ចុះម្ដាយរបស់អ៊ុំគាត់ស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខ៖  ម្ដាយរបស់អ៊ុំគាត់ក៏ស្លូតដែរនឹង ហើយគាត់រាប់អានញ្ញាតិណាស់
ពីព្រោះឪពុករបស់ខ្ញុំគាត់ដាំដើមល្ពៅហាសធំៗ ហើយមាននោងអី
មានបងប្អូនដើរចឹងស្រែកហៅអោយគេមកយកហើយនឹងយកបន្លែយកទៅហូបចឹង

ក៖  ពួកគាត់ចូលចិត្តដាំដំណាំណាអ៊ុំ?

ខ៖  នឹងហើយខ្ញុំឃើញគាត់ដាំច្បាស់ គាត់ដាំមិនខ្វះអីហូបទេ ដាំតាំងពីននោង ល្ពៅ ត្រសក
មានពោត

ក៖  បាទល្អដែរតាអ៊ុំ?

ខ៖  ពួកគាត់មានដាំច្រើន

ក៖  ចុះអ៊ុំមានចងចាំសាចរឿងអីកាលពីអ៊ុំនៅជាមួយពួកគាត់ហាស
ថាអ៊ុំមានចងចាំអនុស្សាវរីយ៍អីដែរធ្លាប់បានធ្វើជាមួយគ្នាអីចឹង?

ខ៖  ខ្ញុំគ្មានរឿងអីទេ មានតែរឿងល្អៗហាស ពេលដែរគាត់ទៅធ្វើស្រែខ្ញុំទៅជួយរើសស្មៅ ជួយរើសមែកឈើអីចេញពីស្រែចឹង ពេលដែរគាត់ទៅចឹងយើងជួយស្ទូង មានអនុស្សាវរីយ៍ដែរថាដកស្ទូងនឹងមានដែរ

ក៖  នឹងជាអនុស្សាវរីយ៍ជាមួយគាត់ណាអ៊ុំ?

ខ៖  នឹងជាអនុស្សាវរីយ៍ជាមួយគាត់ដែរខ្ញុំដឹងហើយនឹង កាលពីខ្ញុំនៅតូចនឹង ម៉ែបានយកខ្ញុំទៅដាក់នៅភ្លឺស្រែ

ក៖  ម៉េចបានគាត់យកទៅដាក់នៅស្រែអ៊ុំ?

ខ៖  នឹងពេលដែរគាត់ចុះស្ទូងនឹងស្រមោចបានខាំខ្ញុំគាត់ប្រាប់ហាស នឹងជាអនុស្សាវរីយ៍ចឹង បើអនុស្សាវរីយ៍ដែរសំខាន់នឹងមានតែប៉ុណ្ណឹងឯង

ក៖  អ្ហូ!មានតែប៉ុណ្ណឹងទេ?

ខ៖  នឹងហើយរហូតបានស្រូវច្រូតអីនឹងយើងបរទេះទៅច្រូតស្រូវ ម៉ែអ្នកច្រូត ឪអ្នកបែនជើងចេះ កាលពីដើម ហើយគាត់ក្រាលកន្ទេលអោយខ្ញុំនៅអង្គុយច្រៀងហាសណាស់

ក៖  អ្ហូ!ចឹងហោស?

ខ៖  នឹងដេកច្រៀងដែរនឹង

ក៖  ចុះកាលគាត់ស្លាប់នឹងទាន់ពលពតអត់អ៊ុំ?

ខ៖  អត់ទាន់ទេ

ក៖  អ្ហូ!អត់ទាន់ទេណាអ៊ុំ?

ខ៖  អត់ទាន់ទេនឹង

ក៖  អ្ហូ!ចឹងគាត់ស្លាប់មុនហោសអ៊ុំ?

ខ៖  គាត់ទាន់ជំនាន់អ៊ីសារ៉ាក់

កៈ  គាត់ទាន់ជំនាន់អ៊ីសារ៉ាក់ ប៉ុន្តែជំនាន់លុណនុលក៏អ៊ុំមិនទាន់ដែរ?

ខៈ  ជំនាន់លុណនុលក៏មិនទាន់ដែរ

កៈ  គាត់ស្លាប់មុនទាំងពីរនាក់តែម្តងហោសអ៊ុំ?

ខៈ  នឹងហើយទាំងពីរនាក់នឹង គាត់ស្លាប់មុនលុណនុល

កៈ  ចឹងឪពុកស្លាប់មុនហោសអ៊ុំ?

ខៈ  ឪពុកស្លាប់ក្រោយ

កៈ  ចឹងម្តាយរបស់អ៊ុំស្លាប់មុន?

ខៈ  ស្លាប់មុនតាំងពីខ្ញុំអាយុ១៩ឆ្នាំ

កៈ  ចឹងម្តាយស្លាប់មុនអ៊ីសារ៉ាក់ ហើយឪពុកស្លាប់មុនលុណនុល?

ខៈ  នឹងហើយស្លាប់មុនលុណនុល

កៈ  ចុះគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំអត់ទេអ៊ុំ ម្តាយរបស់អ៊ុំ?

ខៈ  ម្តាយរបស់អ៊ុំគាត់ជាអ្នកកសិករគាត់ដូចជាគ្មានប្រវត្តិអីច្រើនទេ
ឯប្រវត្តិឪពុកវាលក្ខណះគួរសមដែរគាត់មានជំរឺ

កៈ  អីគាត់មានជំរឺហោសអ៊ុំ?

ខៈ  គាត់មានជំរឺអាសុខៗគាត់មានជំរឺមួយ គាត់រកស៊ីគួរសមដែរ
ហើយឪពុករបស់អ៊ុំនឹងគាត់មិនមានជំរឺទេ ប៉ុន្តែគាត់ក៏ជាអ្នករកស៊ីស្លូតបូតដែរ

កៈ  នឹងពីប្រវត្តិរបស់គាត់កាលពីនៅក្មេងនឹងហោសអ៊ុំ?

ខៈ  នឹងកាលគាត់នៅក្មេង

កៈ  ចុះកាលពីគាត់នៅក្មេងគាត់ធ្លាប់ដើរលេងជាមួយមិត្តភក្តិ រឺធ្វើអីជាមួយមិត្តភក្តិទេ?

ខ៖ បើតាមពិតមិនមានទេ ចាស់ពីដើមដូចជាមិនពិបាកដូចយើងសព្វថ្ងៃនឹងទេ គេទៅណាមកណាក៏ស្ដាប់ឪពុកម្ដាយណាស់

ក៖ វាមិនដូចក្មេងឥឡូវទេណាអ៊ុំ?

ខ៖ នឹងហើយតាមខ្ញុំដឹងទៅក្មេងអ្នកស្រុកស្រែវាស្លូតបូតណាស់ មិនបានគិតទៅណាវែងឆ្ងាយទេ

ក៖ ចុះកាលពីជំនាន់ណុងខ្ញុំចាំថាគេមិនទាន់ចាយលុយទេណាអ៊ុំ?

ខ៖ គេចាយហើយនឹង

ក៖ អូះគេចាយហើយណាអ៊ុំ?

ខ៖ អើរ!!គេចាយហើយ គេចាយហើយគេចាយអាលក្ខណះសេនក្រហមនឹង

ក៖ អូ៎!គេចាយសេនក្រហម?

ខ៖ ប៉ុន្តែអ៊ុំមិនទាន់ផង អ៊ុំទាន់ជំនាន់ជប៉ុននឹងនៅសង្គ្រាមលោកលើកទី២នឹងឆ្នាំ១៩៤០នឹង

ក៖ អូ៎!ទាន់សង្គ្រាមលោកលើកទី២?

ខ៖ នឹងខ្ញុំទាន់តាលុយជប៉ុនសៗមានប្រាក់កាក់ប្រាក់រៀលនឹង

ក៖ លុយចឹងលុយជប៉ុននឹងហោស?

ខ៖ នឹងហើយលុយចឹងឯង លុយជប៉ុនវាសៗៗចឹង

ក៖ នឹងសុទ្ធតែលុយជប៉ុននឹងហោសអ៊ុំ?

ខ៖ ហើយអ៊ុំទាន់ហើយនៅសង្គ្រាមលោកលើកទី២នឹងអ៊ុំទាន់ អ៊ុំអាយុ១២ឆ្នាំហើយ

ក៖ អូ៎!អ៊ុំអាយុ១២ឆ្នាំហោស?

ខ៖ នឹងហើយប៉ុនណុង

ក៖ ចុះអ៊ុំមានស្គាល់ជីដូនជីតាខាងម្ដាយរបស់អ៊ុំទេ?

ខ៖  ខ្ញុំស្គាល់តា

ក៖  ចុះជីដូនជីតាខាងម្ដាយឡគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  តាខាងម៉ាក់នឹងគាត់ឈ្មោះតា កាន់

ក៖  ចុះយាយវិញអ៊ុំ?

ខ៖  យាយឈ្មោះយាយ អៀម

ក៖  គាត់ឈ្មោះយាយ អៀម ចុះពួកគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖  ណុងគាត់កើតនៅស្រុកគិរីវង្សនឹងដែរប៉ុន្ដែនៅឃុំផ្សេងគ្នា

ក៖  នៅឃុំអីគេដែរអ៊ុំ?

ខ៖  នៅភូមិបាឡី ឃុំក្រពែង នឹងនៅខាងលិចភ្នំនឹងនៅស្រុកគិរីវង្ស នៅខេត្តតាកែវដូចតែគ្នាទេ
ដល់ពេលចឹងគាត់មកជួបជុំជាមួយប៉ារបស់ខ្ញុំនឹងនៅខាងភូមិរាមអណ្ដើក
នឹងនៅខាងកើតភ្នំវិញ

ក៖  ចុះជីដូនជីតាខាងឪពុកវិញអ៊ុំមានស្គាល់ដែរទេ?

ខ៖  ស្គាល់ទេ

ក៖  ពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  គាត់មានឈ្មោះយាយណូ នឹងតាប៉ា

ក៖  ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖  គាត់កើតនៅភូមិរកា ឃុំរាមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវនឹង

ក៖  ចុះអ៊ុំមានដឹងអីពីរឿងពួកគាត់ទេ ពីយាយតាខាងម្ដាយ នឹងខាងឪពុករបស់អ៊ុំអត់?

ខ៖  នៅពេលដែរខ្ញុំធំមក ខ្ញុំឃើញគាត់នៅតែស្រុះស្រួលគ្នាធ្វើស្រែនឹងចំការនឹង
ដូចជាមិនសូវជាការខ្វះខាតអីទេ

កៈ ប៉ុន្តែម្តាយឪពុករបស់អ៊ុំហាស គាត់មានដែរប្រាប់ថាអូយ៉ាងម៉េចដែរ ដូចជាគាត់មានធ្លាប់ធ្វើអីគេខ្លះចឹងហាស គាត់មានដែរប្រាប់ទេ?

ខៈ មិនមានទេ មានតែធ្វើស្រែចំការនឹង

កៈ មានតែធ្វើស្រែចំការហោសអ៊ុំ?

ខៈ គាត់ធ្វើតែស្រែចំការមិនដែរមានទាស់ទែងអីគ្នា រឺក៏ខ្វែងគំនិតអីគ្នាទេចាស់ៗពីដើមនឹងរាប់អានរាក់ទាក់គ្នាទាំងភូមិនឹង

កៈ ត្រូវអ៊ុំមិនដូចឥឡូវនឹងទេណាអ៊ុំ?

ខៈ នឹងហើយយ៉ាងណាមួយខ្មែរពីមុនគាត់កាន់សាសនាព្រះពុទ្ធនោះអី លក្ខណៈចូលឆ្នាំ រឺក៏ភ្ជុំអីនឹងទៅវត្តសប្បាយជាមួយគ្នាហាស

កៈ ពិតជាត្រូវមែនអ៊ុំ?

ខៈ ហើយនៅស្រុកអ៊ុំមានទឹកហាស នៅខែភ្ជុំអីយើងមានទូកចឹងដឹកនុំ ចេកអីអោយយាយៗយកទៅវត្តអីនឹង

កៈ អូ៎!សប្បាយហាសណាអ៊ុំ?

ខៈ នឹងហើយសប្បាយណាស់

កៈ ចុះក្រុមគ្រួសាររបស់អ៊ុំនឹងមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ ទើបតែតាំងពីជំនាន់អ៊ុំទេ

កៈ អូ៎!តាំងពីជំនាន់អ៊ុំហោស?

ខៈ នឹងហើយតាយាយ ម៉ាក់ប៉ាអីពួកគាត់នៅផ្ទះទាំងអស់នឹង ទើបតែពីជំនាន់អ៊ុំនៅឆ្នាំហុកជាងនឹងទេណាស់

កៈ ចឹងនៅឆ្នាំហុកជាហោសអ៊ុំ?

ខៈ បាទអ៊ុំមកធ្វើការនៅឆ្នាំ១៩៦០

កៈ ចឹងមានន័យថាអ៊ុំមកនៅតាំងពីឆ្នាំ១៩៦០ ចឹងមានន័យថាអស់៦៨ឆ្នាំហើយចឹង?

ខៈ ប្រហែលជាជាង៥០ឆ្នាំហើយ

កៈ ខ្ទង់ជាង៥៨ឆ្នាំនឹងហើយ អូ៎ច្រើនឆ្នាំ?

ខៈ នឹងហើយពីមុនអ៊ុំទៅធ្វើការនៅភ្នំពេញ ពីមុនអ៊ុំធ្វើជាគ្រូបង្រៀនតា

កៈ អូ៎! អ៊ុំធ្វើជាគ្រូបង្រៀនហោសអ៊ុំ?

ខៈ នឹងហើយពេលដែរសឹកពីបួសមក

កៈ ពេលដែរអ៊ុំសឹកហើយអ៊ុំធ្វើជាគ្រូតែម្តង?

ខៈ នឹងហើយ ហើយខ្ញុំទៅបង្រៀនបាន៣ឆ្នាំ អ៊ុំនៅបង្រៀននៅសាលាចិនមួយខែបានប្រាក់ខែ១៣០០រៀលហាស

កៈ បានប្រាក់ខែ១៣០០រៀលហោស?

ខៈ ហើយពេលដែរបង្រៀននៅសាលាចិន ចឹងទៅបើគេមិនរកមិនដាច់ពោះ ដល់ពេលចឹងអ៊ុំសុខចិត្តបោះចោលអាប្រាក់ខែ១៧០០រៀល ហើយមកយកប្រាក់ខែ១៣០០នឹងវិញ

កៈ អូ៎! ចឹងហោសអ៊ុំ?

ខៈ សុខចិត្តចោលនឹងវាចឹង

កៈ បាទអ៊ុំវាល្អដែរនឹង?

ខៈ ដល់ពេលធ្វើតាំងពីណុងមកបានមានប្រាក់អាត្រេតសព្វថ្ងៃនឹងណា

កៈ ចឹងរាល់ថ្ងៃនឹងអ៊ុំមានប្រាក់អាត្រេត?

ខៈ មានតា ប្រាក់អាត្រេតបាន៤០០០០០រៀលដែរនឹង

កៈ អូ៎!ចឹងមួយខែបានមួយរយដុល្លាដែរហោសអ៊ុំ?

ខ៖ នឹងហើយបានមួយរយដែរនឹង

ក៖ អូ៎!មានអីច្រើនដែរនឹងហាស?

ខ៖ នឹងហើយគ្រាន់តែបានប្រាក់ខែនឹងបានទប់ទល់ដែរនឹង

ក៖ ចឹងគ្រាន់បានទប់ទល់ជាមួយផ្ទះនឹង ?

ខ ៖ នឹងហើយ

ក៖ ចុះអ៊ុំគិតថាមានសាច់ញ្ញាតិណាដែរគិតថាពួកគាត់ទៅរស់នៅក្រៅប្រទេស ដែរនៅក្រៅពីស្រុកខ្មែរហោសអ៊ុំមានទេ?

ខ៖ មានតែអាវីមួយទេ

ក៖ កូនរបស់អ៊ុំចុះគាត់នៅណាដែរអ៊ុំ?

ខ៖ គេនៅឡុងប៊ីច

ក៖ គាត់នៅឡុងប៊ីច នៅប្រទេសអាមេរិចណាអ៊ុំ?

ខ៖ នឹងហើយនៅប្រទេសអាមេរិច កាលពីខែមុនគាត់មកលេងបានកន្លះខែដែរ ហើយមកលេងសៀមរាបបាន២យប់ដែរ គិតទៅដាក់ច្បាប់បានកន្លះខែពីរនាក់ប្តីគេនឹង

ក៖ អូ៎!គាត់ដាក់ច្បាប់អត់ធ្វើការហោសអ៊ុំ?

ខ៖ នឹងហើយដាក់ច្បាប់គិតទៅមកនេះបានតែ១០ថ្ងៃទេ ចុះជិះយន្តហោះអស់មួយថ្ងៃជាងបាត់ទៅហើយនឹង

ក៖ អូ៎!គ្រាន់តែជិះយន្តហោះអស់មួយថ្ងៃហើយ?

ខ៖ ជិះអស់មួយថ្ងៃគិតទៅមកនេះបានតែជាង១០ថ្ងៃទេនឹង

ក៖ ចុះភរិយារបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ភរិយារបស់អ៊ុំមានឈ្មោះពៅវណ្ណារិន

កៈ  គាត់មានឈ្មោះពៅវណ្ណារិន
ចុះអ៊ុំមានចងចាំថាអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយភរិយារបស់អ៊ុំនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខៈ  ខ្ញុំរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៩

កៈ  អូ្!អ៊ុំរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៧៩ហោសអ៊ុំ?

ខៈ  នឹងហើយបើអ៊ុំស្រីមុនគាត់ស្លាប់បាត់ហើយ

កៈ  អូ្!ចឹងមានន័យថាអ៊ុំមានប្រពន្ធពីរនាក់?

ខៈ  ខ្ញុំមានប្រពន្ធពីរនាក់ កាលពីអ៊ុំស្រីមុននឹងគាត់ស្លាប់នៅជំនាន់អាពតហោស
ហើយដល់ពេលដែរមកដល់វិញនឹងក៏បានជួបនឹងម៉ែអាភានឹងទៅ

កៈ  ចឹងពេលដាច់ពលពតហើយបានអ៊ុំមកជួបនឹងអ៊ុំស្រីនឹង?

ខៈ  ហើយអ៊ុំក៏បានមករៀបអាពាហ៍ពិពាហ៍នៅទួលទំពុងនឹង
អ៊ុំបានចាប់ផ្ទះនៅទួលទំពុងនឹងទៅ
តែឥឡូវនឹងផ្ទះនឹងលក់អស់ហើយផ្ទះនឹងបានចែកកូនចៅអស់ហើយនឹង

កៈ  ប៉ុន្តែអ៊ុំមានចងចាំថ្ងៃខែដែរអ៊ុំការទេ?

ខៈ  ថ្ងៃខែដែរអ៊ុំការអ៊ុំមិនសូវចាំទេភ្លេចអស់ហើយនឹង

កៈ  ប៉ុន្តែអ៊ុំដឹងតែឆ្នាំទេ?

ខៈ  នឹងហើយដឹងតែឆ្នាំ១៩៧៩

កៈ  ចុះប្រពន្ធរបស់អ៊ុំមុន អ៊ុំការតាំងពីឆ្នាំណាដែរអ៊ុំ?

ខៈ  ប្រពន្ធរបស់អ៊ុំមុន អ៊ុំការតាំងពីឆ្នាំហាជាងហោសប្រហែលជាឆ្នាំ១៩៥៧អីណោះ
ហើយការបានប៉ុន្មានឆ្នាំនឹងហើយចូលឆ្នាំ១៩៦០នឹង ហើយកាលណុងខ្ញុំនៅបង្រៀននឹង
ទៅបានឆ្នាំ១៩៦០បានខ្ញុំចេញមកភ្នំពេញចឹង

កៈ  ចឹងឆ្នាំ១៩៦០អ៊ុំមកទីក្រុងភ្នំពេញ?

ខ៖  បាទ ខ្ញុំបានកូនពីរហើយនឹងបានខ្ញុំចេញមកភ្នំពេញនឹង

ក៖  ចុះកាលពីប្រពន្ធរបស់អ៊ុំមុននឹងអ៊ុំមានកូនដែរទេអ៊ុំ?

ខ៖  ខ្ញុំមានកូន៥

ក៖  ហើយដល់ពេលដែរសារក្រោយនេះបានអ៊ុំមានកូន២នាក់ទៀត?

ខ៖  នឹងហើយដល់ពេលក្រោយបានកូន២នាក់ទៀតនឹង

ក៖  បងភា នឹងបងរី?

ខ៖  ទាំងអស់ខ្ញុំមានកូន៧នាក់

ក៖  ប៉ុន្តែកូនរបស់អ៊ុំទាំង៥នាក់នឹងគាត់នៅណាដែរអ៊ុំ?

ខ៖  មានកូនមួយនៅខាងលិចផ្សារ ហើយនៅព្រែកហូរមាន៣នាក់

ក៖  ចឹងមាននៅព្រែកហូរនឹង៣នាក់?

ខ៖  មាននៅចាក់អង្រែនឹងម្នាក់ទៀត

ក៖  អូ៎!កូនរបស់អ៊ុំដែរថាលក់អីៗនៅលើនឹងមែនអ៊ុំ?

ខ៖  នឹងហើយកូនប្រុសនឹងកូនរបស់ខ្ញុំ ហើយកូនស្រីជាកូនប្រសារ

ក៖  ប៉ុន្តែគាត់នៅតែរាប់អានជាមួយអ៊ុំរាល់ថ្ងៃនឹង?

ខ៖  នឹងហើយយកម្ហូបអោយខ្ញុំជារៀងរាល់ថ្ងៃនឹង

ក៖  ចឹងគាត់នៅតែមកលេងអ៊ុំជារៀងរាល់ថ្ងៃនឹងទៅ?

ខ៖  នឹងហើយនៅតែមកលេងសឹងជារៀងរាល់ថ្ងៃនឹងដែរ
កូនរបស់អ៊ុំគាត់មិនបោះបង់ចោលឪពុកទេនៅតែមកលេងនឹង

ក៖  ទោះគាត់ដឹងថាអ៊ុំមានប្រពន្ធមួយទៀតក៏ដោយ?

ខ៖  គាត់នៅតែស្រលាញ់ម៉ែអារី នឹងម៉ែអាភានឹងដូចតែម៉ែគាត់ដែរនឹង

ក៖  ចឹងគាត់ស្រលាញ់បងរី នឹងបងភាដូចជាបងប្អូនហោសអ៊ុំ?

ខ៖  នឹងនៅតែស្រលាញ់គ្នាដូចជាបងប្អូនចឹង ប៉ុន្តែគេមានប្តីប្រពន្ធអស់ហើយនឹង ប៉ុន្តែគេនៅរកស៊ីរៀងខ្លួនចឹងហាសណាស់

ក៖
ប៉ុន្តែនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបអោយដែរអ៊ុំ?

ខ៖  ម្តាយឪពុក ហើយដល់ពេលម៉ែអារី នឹងអាភានឹង
ក៏បងប្អូនរបស់គេជាអ្នករៀបចំអោយដែរនឹង

ក៖
ប៉ុន្តែនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាម្តាយឪពុករបស់អ៊ុំជាអ្នកដែររៀបចំអោយរឺមួយក៏អ៊ុំជាអ្នករៀបដោយចិត្តឯងដែរ?

ខ៖  កាលណុងឪពុកម្តាយរបស់ខ្ញុំជាអ្នកដែរដណ្តឹងអោយ

ក៖  ពួកគាត់ជាអ្នកដែរដណ្តឹងអោយហោសអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  ចុះអ៊ុំមានជាថ្លៃបណ្ណាការអោយគាត់ដែរទេ?

ខ៖  កាលណុងមានតា

ក៖  អូ៎!មានបណ្ណាការដែរហោសអ៊ុំ?

ខ៖  មានតែប៉ុន្មាននឹងខ្ញុំវាភ្លេចអស់ហើយនឹង

ក៖  ចុះកាលណុងមានច្រើនអត់អ៊ុំមានចងចាំទេ?

ខ៖ តាមពិតកាលណុងវាមានច្រើនដែរនឹងហាស វាមានជ្រូកនឹងម្ហូបអាហារអីនឹង
ខាងស្រីគេជាអ្នកចេញសំរាប់យើងត្រៀមតែលុយទៅបានហើយ

ក៖ អូ៎!ច្រើនដែរនឹង ចុះអ៊ុំអាចប្រាប់ខ្ញុំបន្តិចបានទេថាពេលណាដែរអ៊ុំបានជួបភរិយារបស់អ៊ុំ
ហើយនៅពេលណាដែរអ៊ុំគិតថាបានស្រលាញ់គាត់ នឹងជួបពេលណា
នឹងចង់រៀបការជាមួយកាត់ដែរចឹងហាសអ៊ុំ?

ខ៖ នឹងនិយាយតែអ៊ុំក្រោយ?

ក៖ ទាំងមុនទាំងក្រោយអ៊ុំ អ៊ុំអាចនិយាយអ៊ុំមុនតិចទៅ

ខ៖ អានឹងប្រហាក់ប្រហែលគ្នាទេ អ្វីដែរសំខាន់បំផុតនឹងយើងមើលអាកាប្បកិរិយា
នឹងពូជអំបូររបស់គេ ហើយគេជាអ្នកស្លូតបូតចឹងទៅ
ហើយសំខាន់នឹងយើងយកអ្នកដែរដឹងខុសត្រូវ

ក៖ បាទត្រូវហើយអ៊ុំ

ខ៖ គេថាយកតាមពូជនឹងអំបូរចឹងទៅ

ក៖ ប៉ុន្តែអ៊ុំមានស្គាល់គ្នាយូរអត់អ៊ុំបានជាអ៊ុំចូលស្ដីអ៊ុំស្រីចឹងទៅ?

ខ៖ នេះសុទ្ធតែសំគាល់យូរដែរនឹង នឹងល្មមនឹងយើងដឹងចិត្តគ្នាចឹង
តែឥឡូវនឹងគេដើរលេងចឹងទៅ

ក៖ បាទត្រូវហើយអ៊ុំ?

ខ៖ កាលពីជំនាន់ណុងគេមិនបានដើរលេងទេ យើងគ្រាន់តែសំគាល់ហើយ
យើងអោយចាស់ទុំចូលស្ដីរតែម្ដងនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ អ៊ុំបានចេះអក្ខរវិរុតគួរសមដែរ

ក៖ ចឹងអ៊ុំចេះគួរសមដែរ?

ខ៖  នឹងហើយមិនចេះជាណាស់ណាដែរទេ ដោយសារតែអ៊ុំចេះសរសេរបានល្អដោយសារតែអ៊ុំបានរៀនបាលី

ក៖  ចឹងអ៊ុំបានចេះដោយសារតែអ៊ុំរៀនបាលី?

ខ៖  នឹងហើយអ៊ុំបានបួសអស់៧ឆ្នាំនឹងដោយសារតែអ៊ុំរៀនបាលី ទោះថាវាភ្លេចអស់ច្រើនប៉ុន្តែយើងក៏នៅតែចាំបានខ្លះដែរនឹង

ក៖  ប៉ុន្តែអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖  អត់មានចេះទេបានតែមួយនឹង

ក៖  អ៊ុំចេះតែខ្មែរនឹង អ៊ុំអត់មានចេះភាសាវៀតណាម រឺមួយក៏ថៃអីទេ?

ខ៖  អត់ចេះទេ កាលពីនៅក្មេងនឹងខ្ញុំរៀនភាសាបារាំងដែរប៉ុន្តែវាមិនអាចប្រើការបាន

ក៖  អូ៎!អ៊ុំបានភ្លេចហើយ?

ខ៖  នឹងហើយ អង ឌឺ ទ្រ កាត់ សែ ស៊ីសអីនឹងភាសាបារាំង

ក៖  ចុះកាលពីអ៊ុំរៀនខ្មែរនឹង តើអ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំបានអ៊ុំឈប់រៀនចឹង?

ខ៖  ខ្ញុំរៀនបានតិចណាស់ រៀននៅសាលាវត្ត អត់បានចូលសាលាបឋមសិក្សាអីទេ ចូលរៀនតែសាលាវត្តនឹង

ក៖  ចឹងអ៊ុំរៀនតែនៅលាសាវត្តទេ?

ខ៖  នឹងហើយកាលណុងគេរៀនក្តារវែងៗណាស់

ក៖  ប៉ុន្តែកាលពីរៀននៅសាលវត្តនឹងអ៊ុំរៀននៅណាវិញអ៊ុំ?

ខ៖  រៀននៅវត្តគោករកានឹង

ក៖  វត្តគោករកានៅណាវិញអ៊ុំ?

ខ៖  នៅឃុំគោកអណ្តើក ស្រុកគិរីវង្ស ខេត្តតាកែវនឹង

ក៖ ប៉ុន្តែឈ្មោះសាលានៅក្នុងវត្តនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ នឹងនៅវត្តតែម្តងនឹង

ក៖ ប៉ុន្តែវត្តនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ វត្តនឹងអត់មានសាលាទេ រៀននៅលើសាលាឆាន់

ក៖ ប៉ុន្តែវត្តនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះវត្តគោករកា

ក៖ ចឹងវត្តនឹងមានឈ្មោះថា វត្តគោករកាចឹងតែម្តង
ចុះអ៊ុំធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖ អាមិត្តភក្តិជិតស្និទ្ធិនឹងមានតែមួយទេ

ក៖ មានតែមួយទេហោសអ៊ុំ ចុះអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ប៉ុន្តែគាត់ស្លាប់បាត់ទៅហើយ

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះយ៉ង យ៉ាន់

ក៖ គាត់ឈ្មោះយ៉ងយ៉ាន់ហោសអ៊ុំ?

ខ៖ យ៉ងយ៉ាន់នឹងយើងស្រលាញ់គ្នាដូចជាបងប្អូនចឹង
ហើយដល់ពេលដែរវាធំឡើងវាទៅធ្វើការងារនៅកំពង់ធំ

ក៖ គាត់ធ្វើអីគេដែរនៅកំពង់ធំនឹង?

ខ៖ វាទៅនឹងនៅបារាយណ៍ ហើយវាមានឪពុកមារបស់វានៅទីនោះ
ហើយឪពុកមាអោយទៅធ្វើការងារនៅស្ទូង ហើយវាក៏មានរោគទៅក៏ស្លាប់ទៅ

ក៖ ចឹងគាត់ស្លាប់ដោយសារតែឈឺ?

ខ៖ នឹងហើយ ស្តាយបើវានៅដល់ឥឡូវនឹងល្អដោយសារតែអាយុវានឹងយើងប្រហែលគ្នាចឹងពេលហៅគ្នាអាទៅអាមក

ក៖ ចឹងមានន័យថាអ៊ុំឆ្នាំដូចគ្នាណាអ៊ុំ?

ខ៖ នឹងហើយឆ្នាំដូចតែគ្នានឹង

ក៖ ចុះអ៊ុំធ្លាប់មានសាច់រឿងអីជាមួយគាត់ដែរទេអ៊ុំ ថាចូលចិត្តធ្វើអីជាមួយគ្នាដែរ?

ខ៖ ទេមិនសូវមានសាច់រឿងអីជាមួយគ្នាទេមានតែលេងល្ខោន

ក៖ អូ៎!អ៊ុំចេះលេងល្ខោនដែរ?

ខ៖ ចេះលេងល្ខោនជាមួយគ្នាសប្បាយណាចាស់ពីដើមគេលេងល្ខោនតាមភូមិហោស គេអ្នកដើរតួស្វា ហើយអ៊ុំដើរតួជាព្រានព្រៃ

ក៖ អូ៎!អ៊ុំដើរតួជាព្រានព្រៃហោសអ៊ុំ?

ខ៖ នឹងហើយយើងបានយកកាំបិតស្នាយនឹង ហើយធ្វើជាកាប់ករគេ ហើយវាមុតកគេនឹងទៅគេថាអោយហេអានេះធ្វើអោយមុតកអញ់ហែង

ក៖ ធ្វើលេងប៉ុន្តែវាត្រូវមែនទែន?

ខ៖ ខ្ញុំប្រាប់ថាអញ់គ្មានបំណងណា បើវាត្រូវមែនទែននឹង

ក៖ ទៅយ៉ាងម៉េចទៅអ៊ុំ?

ខ៖ វាថាអោយហែងអូសយ៉ាងម៉េចក៏ដោយកុំអោយដូចមែនទែនហាស

ក៖ ហើយមុតមែនទែន?

ខ៖ អូ៎!ស្រលាញ់គ្នាណាស់ជាពិសេសនឹងចាស់ពីដើមវាមានលេងអាប៉ោងអីនឹងអ៊ុំអត់ចេះលេងទេប៉ុន្តែវាចេះលេង

កៈ មិត្តភក្តិរបស់អ៊ុំចេះលេងប៉ុន្តែអ៊ុំមិនចេះទេ?

ខៈ នឹងហើយចឹងទៅវាឈ្នះបានច្រើនណាស់
ហើយវាប្រាប់ពីខាងក្រៅថាបើហែងឃើញអញ់ឈ្នះ ហែងត្រូវប្រមូលទុកហាស

កៈ គាត់អោយទុកអោយមែនអ៊ុំ?

ខៈ វាអោយទុកអោយនឹង ហើយនៅពេលដែរចាញ់វិញ

កៈ ពេលដែរចាញ់វិញម៉េចទៅ?

ខៈ ពេលដែរចាញ់វិញវាទាយកលុយទៅលេងវិញ ដល់ពេលចឹងអ៊ុំបានរត់ទៅ
ហើយអ៊ុំក៏រត់តាមដែរនឹងអ៊ុំរត់ទៅអោយឆ្ងាយហើយអ៊ុំប្រាប់ថាឆ្កួតទេអី
បើហែងលេងចាញ់អស់ទៅបានអីចាយទៅ

កៈ អូ៎!សប្បាយណាស់អ៊ុំ?

ខៈ ចឹងក៏វាបានឈប់លេងទៅ វាប្បាយណាស់

កៈ ពេលណុងសប្បាយដែរណាអ៊ុំ?

ខៈ សប្បាយធ្លាប់មានមិត្តភក្តិអនុស្សាវរីយ៍ ដល់ពេលវាស្លាប់ចឹងទៅស្តាយដែរ

កៈ ប៉ុន្តែអ៊ុំមានអនុស្សាវរីយ៍អីផ្សេងទៀតទេពីនឹងផ្សេងទៀត?

ខៈ វាដូចជាមិនមានទេ

កៈ ចឹងអត់មានទេណាអ៊ុំ?

ខៈ អត់មានអីទៀតទេនឹងហោស

កៈ ចុះអ៊ុំធ្លាប់ធ្វើការងារនៅវាលស្រែចំការទេអ៊ុំ?

ខៈ ធ្លាប់ដែរតើ អ៊ុំចេះធ្វើស្រែស្ទាត់ណាស់

កៈ អូ៎!អ៊ុំចេះស្ទាត់ហោសអ៊ុំ?

ខ៖ អ៊ុំចេះធ្វើនង្គ័ល ធ្វើរនាស់សំរាប់ភ្ជួរអីនឹង ខាងភ្ជួរអីអំចេះប្រាកដណាស់ខាងកសិកម្មនឹង អ៊ុំចេះតែម្ដងនឹង

ក៖ ចុះអ៊ុំធ្លាប់ធ្វើអាជីកម្មនៅក្នុងក្រុមគ្រួសារអត់អ៊ុំ ដូចជាអាជីវកម្មចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូកអីចឹងអ៊ុំ?

ខ៖ អត់ទេខ្ញុំមិនដែរទេ

ក៖ ចឹងមានន័យថាអ៊ុំអត់ដែរទេ?

ខ៖ មានដែរមានតែលក្ខណះជាគ្រួសារហោសមានចិញ្ចឹមជ្រូកមួយ នឹងចិញ្ចឹមមាន់៤-៥ អីចឹងទៅ ហើយអោយវារត់លេងពេញភូមិអីចឹងទៅ

ក៖ អោយវារត់លេងពេញភូមិទៅ?

ខ៖ នឹងហើយ

ក៖ ប៉ុន្តែអ៊ុំមានធ្លាប់លក់ដូរអីទេអ៊ុំ?

ខ៖ ខ្ញុំមិនដែរទេ

ក៖ អូ៎!អត់ដែរទេហោសអ៊ុំ ?

ខ៖ រឿងខាងពាណិជ្ជកម្មអត់ដែរមានទេ

ក៖ បាទអ៊ុំ ចុះអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំ?

ខ៖ កាលពីអ៊ុំនៅកំលោះអ៊ុំឡើងត្នោត

ក៖ អូ៎!អ៊ុំជាអ្នកឡើងត្នោតោហោសអ៊ុំ?

ខ៖ អ៊ុំឡើងមួយព្រឹកចឹងអ៊ុំឡើងបាន១០-២០ដើមអីហោស ហើយឡើងអត់មានចងបង្អោងទេ ឡើងទៅកៀបត្នោតហាស

ក៖ អូ៎!អ៊ុំឡើងធម្មតាចឹងតែម្ដង?

ខ៖  នឹងហើយអ៊ុំលក់ទឹកត្នោតនឹងល្អជាងគេ
ខ្ញុំមានមុខរបរតែប៉ុណ្ណឹងដែរប្លែកណាស់ដែរខុសពីធ្វើស្រែគឺធ្វើត្នោត មានតែប៉ុណ្ណឹង

ក៖  ចុះតាំងបីក្មេងរហូតមកដល់ឥឡូវនឹង
តើអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរទៅអ៊ុំ នៅក្នុងជីវិតរបស់អ៊ុំ?

ខ៖  តាមអ៊ុំគិតថាមានការផ្លាស់ប្តូរបានច្រើនដែរ ពីមុនយើងជាមនុស្សល្អដែរតាមបង្គាប់ម៉ែឪ
យើងមិនដើរលេងយប់ យើងមិននិយាយអីអត់ល្អដាក់អ្នកជិតខាង

ក៖  បាទល្អណាស់អ៊ុំ?

ខ៖  យើងមានការស្រលាញ់រាប់អានពូ មីង មា តា យាយ
នឹងអ្នកជិតខាងពេញភូមិនឹងអ្វីដែរខ្ញុំធ្វើនឹងឯងមានចឹង

ក៖  អ៊ុំធ្វើកាលពីអ៊ុំនៅកំលោះហោសអ៊ុំ?

ខ៖  បាទនឹង តែដល់ពេលដែរបច្ចុប្បន្ននេះយើងមានការប្រែបានច្រើន
ដូចថាយើងបានស្គាល់ដំណឹងល្អរបស់ព្រះ

ក៖  អូ៎!ល្អអ៊ុំ?

ខ៖
សំខាន់បំផុតនឹងយើងសប្បាយចិត្តដែរបានដឹងថាដើមកំណើតរបស់យើងនឹងកើតមកពីណា

ក៖  បាទអ៊ុំត្រូវហើយអ៊ុំ

ខ៖  ពេលដែរខ្ញុំនៅបួស ខ្ញុំបានស្រាវជ្រាវរកព្រះគម្ពីរដែរប៉ុន្តែវាមិនឃើញកំណើតមនុស្សទេ

ក៖  អត់ដឹងថាមនុស្សកើតមកពីណាទេ?

ខ៖  នឹងថាមនុស្សកើតមកពីស្វាអីចឹងទៅ

ក៖  នឹងតាមអ្នកវិទ្យាសាស្ត្រហីអ៊ុំ?

ខ៖ នឹងហើយតាមដែរមនុស្សថាទេ
ដល់ពេលដែរយើងបានស្គាល់ដំណឹងល្អរបស់ព្រះអង្គទើបយើងដឹងថាយើងស្គាល់ពីដើមកំ
ណើតខ្លួនឯងនឹងគឺនៅជាមួយព្រះវរបិតាសួគ៌

ក៖ បាទត្រូវនឹងហើយអ៊ុំ

ខ៖ នឹងយើងបានចិត្តគំនិតរបស់យើងកែប្រែច្រើន យើងកាន់តែល្អលើសមុនទៀតដែរ
នឹងហើយចង់អោយប្អូន កូន ចៅអីនឹងចង់អោយពួកគេបានល្អជាងអ៊ុំទៅទៀតនឹង

ក៖ បាទវាល្អសំរាប់កូនចៅយើងណាអ៊ុំ?

ខ៖ មួយទៀតនឹងសំខាន់ណាស់ដែរយើងរកកំណើតរបស់យើងអោយឃើញនឹង
ពេលណាដែរយើងរកឃើញកំណើតរបស់យើងហើយមិនត្រូវធ្វេសប្រហែសទេពីដើមកំណើតរ
បស់យើងទេនឹង

ក៖ បាទត្រូវអ៊ុំ ចុះសព្វថ្ងៃនឹងអ៊ុំចូលចិត្តម្ហូបអីគេដែរអ៊ុំ?

ខ៖ តាមពិតទៅនឹងគ្មានអីជាងត្រីទេនឹង វាចូលចិត្តជាងសាច់គោ នឹងសាច់ជ្រូកអីនឹងហាស

ក៖ ប៉ុន្តែម្ហូបអីដែរអ៊ុំចូលចិត្តលក្ខណះថាដូចជាស្លម្ជូរ ស្ងោរ រឺមួយឆា
កកូរអីចឹងទៅអ៊ុំដែរចូលចិត្តហូប?

ខ៖ ខ្ញុំចូលចិត្តតែស្ងោរទេ?

ក៖ អ៊ុំចូលចិត្តស្ងោរហោសអ៊ុំ?

ខ៖ បាទចូលចិត្តស្ងោរ ហើយនឹងអាំង

ក៖ អូ៎!អ៊ុំចូលចិត្តអាំងដែរត្រី ចុចទឹកត្រីស្វាយអីចឹងទៅអ៊ុំ?

ខ៖ នឹងហើយដែរចូលចិត្តនឹង

ក៖
ចុះគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងជាងគេតាំងពីក្មេងហាសអ៊ុំដូចជាល្បែងទាញ
ព្រាត ចោលឈូង ?

ខ៖ កាលពីនៅក្មេងអ៊ុំចូលចិត្តលេងទាត់សី

ក៖ អូ៎!ចូលចិត្តលេងល្បែងទាត់សីហោសអ៊ុំ?

ខ៖ នឹងហើយល្បែងទាត់សី

ក៖ ចុះលេងបាល់អីអ៊ុំចូលចិត្តលេងទេ?

ខ៖ បាល់មិនសូវបានលេងទេ កាលពីជំនាន់អ៊ុំវាមានតិចណាស់ពីព្រោះវាមិនសូវមានបាល់ទេ មានតែក្តិបត្នោតតើ

ក៖ អូ៎!លេងក្តិបត្នោតអ៊ុំ?

ខ៖ នឹងហើយយកមកទាត់លេង

ក៖ អូ៎!ចឹងឈឺជើងហោសអ៊ុំ?

ខ៖ ឈឺក៏ឈឺសប្បាយក៏សប្បាយដែរ ប៉ុន្តែមិនបានជាអីទេ ប៉ុន្តែអោយលេងទាត់សីនឹងវាចូលចិត្តកំសាន្ត ប៉ុន្តែមិនមែនជាអាជីពទេ

ក៖ ចុះអ៊ុំចងចាំចំរៀងណាដែរអ៊ុំគិតថាអ៊ុំបានរៀនតាំងពីក្មេងហោសអ៊ុំមានទេ?

ខ៖ សំខាន់ណាស់រឿងចំរៀងនឹងអ៊ុំបានច្រៀងអោយយាយតានៅវត្តស្តាប់ យើងច្រៀងត្រពាំងពាយ

ក៖ បទអីគេដែរអ៊ុំ?

ខ៖ បទត្រពាំងពាយនឹង ត្រពាំងពាយអើយងូតទឹកអោយថ្លាខ្យងនឹង ហើយងូតក្បែរបងដុះក្អែរអោយដុះពីមុខ នឹងដុះពីខ្នង

ក៖ កំប្លែងអ៊ុំ?

ខ៖ នឹងកាលពីអ៊ុំនៅក្មេងនឹងអ៊ុំនៅចាំនឹងជាអនុស្សាវរីយ៍នៅវត្តនឹង តែទៅវត្តនឹងគាត់អោយច្រៀងហើយនឹង

ក៖ ចុះមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ដែរទេអ៊ុំ?

ខ៖ រឿងភ្លេងមានតែអាភានឹង

ក៖ ចុះបងភាគាត់ចេះលេងអីគេដែរអ៊ុំ?

ខ៖ លេងភ្លេងព្រះវិហារនឹង

ក៖ លេងភ្លេងព្រះវិហារមានលេងព្យាណូនឹង?

ខ៖ អើរនឹងលេងព្យាណូនឹង មានចេះតែអាភានឹងមួយទេ

ក៖ ក្រៅពីនឹងកូនចៅរបស់អ៊ុំអីនឹងអត់មានចេះទេ បងវីអីគាត់អត់ចេះទេ?

ខ៖ អត់មានចេះទេនឹង
មើលកូនចៅរបស់ខ្ញុំពីមុនក៏អត់មាននរណាគេចេះលេងខាងភ្លេងនឹងដែរ

ក៖ ចឹងចេះតែកូនអ៊ុំបងភាទេ?

ខ៖ នឹងហើយបានតែអាភានឹងឯងដែរចេះ

ក៖ ចុះផ្ទះរបស់អ៊ុំមានលក្ខណះយ៉ាងម៉េចដែរអ៊ុំតាំងពីក្មេងហាសអ៊ុំរហូតមកដល់ឥឡូវនឹង?

ខ៖ ផ្ទះរបស់អ៊ុំ?

ក៖ ថាពីក្មេងនឹងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងយ៉ាងម៉េចចឹងទៅ?

ខ៖ ផ្ទះអ៊ុំចឹងបានអ៊ុំប្រៀបធៀបថាកាលពីតាយាយនឹងផ្ទះវាធំៗណាស់
ហើយមកដល់ជំនាន់ឪពុករបស់ខ្ញុំនឹងខ្ញុំមក មិនដែរទាន់បានមានផ្ទះធំនៅទេ
គ្រាន់តែអាចនៅបានមានទទឹង៤ម៉ែត្រ នឹងបណ្តោយ១០ម៉ែត្រអីចឹងទៅ

ក៖ ចុះផ្ទះថ្មរឺមួយក៏ផ្ទះឈើដែរអ៊ុំ?

ខ៖ ផ្ទះឈើទេនឹង

ក៖ អូ៎!ផ្ទះឈើហោសអ៊ុំ?

ខ៖  មិនទាន់មានផ្ទះថ្មនៅទេ នឹងអ៊ុំបានធ្វើនៅស្ថានីយ៍នឹងផ្ទះថ្មនៅខាងមុខនឹង
ដល់ពេលហើយលក់ក៏អស់ទៅទៀតទៅ

ក៖  ចឹងក៏អត់មានទៀត?

ខ៖  អត់មានទៀតយើងមិនទាន់បានទេ និយាយរឿងផ្ទះសំបែងនឹងមិនទូលំទូលាយទេ

ក៖  ចុះអ៊ុំគិតថាផ្ទះអ៊ុំជាអ្នកសាងសងរឺក៏អ៊ុំជួលគេជាអ្នកសាងសងដែរអ៊ុំ
នៅពេលដែរផ្ទះរបស់អ៊ុំពីមុនចឹងទៅ?

ខ៖  ចង់និយាយថាម៉េចដែរ?

ក៖  គិតថាអ៊ុំរឺឪពុករបស់អ៊ុំជាអ្នកសាងសងរឺមួយក៏អ៊ុំជួលគេដែរ?

ខ៖  បើតាមពិតពីមុនមកនឹងគឺធ្វើតែខ្លួនឯងទេនឹង

ក៖  ផ្ទះអ៊ុំធ្វើតែខ្លួនឯងទេណាអ៊ុំ?

ខ៖  ឪពុកខ្ញុំគាត់ធ្វើតែគាត់នឹងញ្ញាតិជិតខាងគេជួយចឹង
មិនទាន់បានអោយគេជួយធ្វើដូចផ្ទះថ្មអីទេធ្វើតែផ្ទះឈើទេ នៅតែផ្ទះឈើនឹង

ក៖  ចុះនរណាគេជាអ្នកបង្រៀនអោយគាត់ចេះធ្វើរឺក៏គាត់ចេះធ្វើដោយខ្លួនឯង?

ខ៖  នឹងតាមលក្ខណះក្រុមគ្រួសារមកចេះតៗគ្នាចឹងទៅណាស់

ក៖  ចឹងចេះតៗគ្នារហូតទៅណាអ៊ុំ?

ខ៖  នឹងហើយសំរាប់អ៊ុំចេះធ្វើបានល្អនឹងដោយសារតែបួស

ក៖  អ៊ុំចេះពេលដែរអ៊ុំទៅបួស?

ខ៖  នឹងហើយចេះធ្វើពេលដែរគេធ្វើកុត ធ្វើសាលាអីនឹង
ហើយលោកគ្រូចៅអធិការអីនឹងបង្ហាត់បង្រៀនទៅ

ក៖  អូ៎!ល្អដែរតើអ៊ុំ?

ខ៖  ចេះកាន់កាំបិត ពូថៅ ដែកឈូស អីនឹងពេលដែរនៅវត្តនឹងពេលបួសនឹងឯង

ក៖
ចុះអ៊ុំគិតថាពេលដែរគេសាងសងផ្ទះនឹងគេមានប្រើឧបករណ៍អីសំរាប់សាងសងផ្ទះនឹងដែរអ៊ុំ?

ខ៖  មានរណា ដែកឈូស ពន្លាក ពូថៅ

ក៖  មានដែកដាប់អីចឹងទៅ?

ខ៖  ដែកដាប់នឹងពន្លាកនឹងហើយ មានមួយគ្រប់ដែរអ៊ុំចេះនឹង

ក៖  មានដែកគោលអីចឹងទៅ?

ខ៖  មានដែកគោលមានអីនឹង

ក៖  មានឈើអីនឹងដែរណាអ៊ុំ?

ខ៖  មានមានទាំងអស់នឹង

ក៖  ប៉ុន្តែធ្វើពីស័ង្កសីណាអ៊ុំ?

ខ៖  អ៊ុំធ្វើតាំងពីផ្ទះប្រកស្លឹកឡើងនឹង ធ្លាប់ធ្វើប៉ុន្តែមិនទាន់បានផ្ទះធំដុំនៅឡើយទេ
កាលពីនៅស្រែក៏ចឹងដែរផ្ទះឈើប្រកស្លឹក នឹងស័ង្កសី

ក៖  បាទអ៊ុំ
ចុះអ៊ុំធ្លាប់បានរៀនពីជំនាញអីពីក្រុមគ្រួសាររបស់អ៊ុំធ្លាប់បានបង្រៀនពីជំនាញអីទៅអ៊ុំទេដូចជាជំនាញវេញវល្លិ៍ រឺក៏កូរស្ករ
រឺជំនាញអីផ្សេងៗទេដែរអ៊ុំគិតថាម្តាយឪពុករបស់អ៊ុំគាត់បានបង្រៀនទៅអ៊ុំចឹង
លក្ខណះធ្វើម្ហូបក៏បាន រឺលក្ខណះថាធ្វើអីមួយចឹងទៅ?

ខ៖
គាត់មិនបានបង្រៀនយើងពីរឿងធ្វើម្ហូបអាហារអីទេនឹងគាត់បង្រៀនច្បាស់លាស់នឹងពីរបៀបធ្វើស្រែ បង្រៀនពីរបៀបកាន់នង្គ័ល ចេះធ្វើរនាស់អីនឹងទៅ

លក្ខណៈថាជាឧបករណ៍ធ្វើស្រែអីនឹងគាត់បង្រៀនច្បាស់លាស់ ប៉ុន្តែរឿងខាងម្ហូបអីនឹងមិនបានបង្រៀនទេ

ក៖ ចឹងអ៊ុំអត់ចេះទេ?

ខ៖ បាទខ្ញុំមិនបានចេះទេ

ក៖ លក្ខណៈកូរស្ករ វេញវល្លិ៍អីអ៊ុំមានចេះទេ ត្បាញក្រម៉ាអីអ៊ុំ?

ខ៖ មិនចេះទេ ចេះតែជួយម៉ែពេលដែរគាត់ធ្វើហូលអីនឹង ចេះតែជួយគាត់បាន តែអោយចេះខ្លួនឯងតែម្តងនឹងអត់ចេះទេ

ក៖ ចុះអ៊ុំអាចប្រាប់ខ្ញុំបានទេថាអ៊ុំមានការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរទេ?

ខ៖ ការលំបាកដូចជាមិនមានទេ
បើមាននឹងមានតែពេលដែរសង្គ្រាមកាលពីជំនាន់អ៊ីសារ៉ាក់នឹងពិបាក

ក៖ មានអ៊ីសារ៉ាក់ លុនណុល ពលពត?

ខ៖ នឹងពលពតនឹងមានសង្គ្រាមនឹងលំបាកហោស យើងត្រូវអត់ឃ្លាន
យើងត្រូវគេចវេសពីគ្រាប់ផ្លោង ពីរំសេវអីនឹងចឹងទៅ
ហើយនឹងចូលពួននៅក្នុងព្រៃអីនឹងទៅកាលលំបាកមានតែប៉ុណ្ណឹងទេ

ក៖ ក្រៅពីនឹងកាលលំបាកនៅក្នុងផ្ទះអីអត់មានទេណាអ៊ុំ?

ខ៖ អត់មានទេលំបាកនៅក្នុងផ្ទះនឹងអត់មានទេ

ក៖ ចុះអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ មើលការលំបាកនឹងពេលដែរជំនាន់ពលពតយើងមិនអត់បាយ
អត់បាយហើយយើងគ្មានសេរីភាពក្នុងការដើរហើរទៀតនឹង

ក៖ បាទត្រូវអ៊ុំ

ខ៖ បើនៅណាមួយគឺនៅតែណុងហើយពីព្រោះអីយើងត្រូវគោរពលក្ខខ័ណ្ឌប្រតិបត្តិរបស់គេ វាអោយទៅកាប់ដីទាំងយប់អត្រានឹងក៏មានដែរ មានការលំបាកតែប៉ុណ្ណឹងទេ ពិបាកពេលដែរសង្គ្រាមនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំមានបទពិសោធន៍ល្អៗអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរដូចជាអ៊ុំបានរៀបអាពាហ៍ពិពាហ៍ រឺក៏អ៊ុំបានរៀបអាពាហ៍ពិពាហ៍អោយកូនចៅដែរអ៊ុំគិតថាជាពេលដែរអ៊ុំសប្បាយជាងគេនៅក្នុងជីវិតរបស់អ៊ុំដែរចឹងអ៊ុំ?

ខ៖ ត្រឹមត្រូវហើយដែរថាខ្ញុំមានសំណាងបានការងារទាំងមុនទាំងក្រោយបាស បានរៀបចំពីមុនបានមានភ្លេងមានអីសព្វគ្រប់នឹងដូចចាត់ទុកក្នុងមង្គលការយើងដែរនឹងវាធំដុំដែរនឹង

ក៖ បាទល្អដែរអ៊ុំ?

ខ៖ នឹងហើយប៉ុន្តែពេលក្រោយនេះយើងមិនបានរៀបចំអីទេ ប៉ុន្តែយើងមានសេរីភាពគ្មាននរណាគេមកបង្ខិតបង្ខំអីទេ អោយកូនចៅមានសុខដំរម្យនា គ្មានការឈ្លោះទោសទែងវៃគ្នាអីអត់មានទេនឹង

ក៖ អូ៎!ល្អមែនអ៊ុំ

ខ៖ មានតែចេះស្រលាញ់គ្នា ខ្ញុំឃើញថាល្អ

ក៖ ចឹងបទពិសោធន៍របស់អ៊ុំមានការរៀបអាពាហ៍ពិពាហ៍ខ្លួនឯងនឹងមានការរៀបអាពាហ៍ពិពាហ៍អោយ កូនចៅ?

ខ៖ នឹងហើយមានកូនចៅនឹងហើយ

ក៖ ហើយនឹងសប្បាយជាមួយចៅៗអីចឹងទៅ?

ខ៖ នឹងហើយបានរៀបអោយកូនចៅអីដូចអាភាអីនឹង

ក៖ ចុះពេលដែរតាំងពីក្មេងអ៊ុំមានធ្លាប់មានក្ដីសង្ឃឹមថាពេលដែរអ៊ុំធំឡើងអ៊ុំចង់ធ្វើអីគេដែរទេលក្ខណៈថា ចង់ធ្វើជាគ្រូពេទ្យ រឺមួយក៏ចង់ធ្វើជាអ្នកជំនាញរកស៊ីអីមួយ រឺមួយក៏ចង់ធ្វើជាគ្រូបង្រៀនអីចឹងទៅនឹង ធ្លាប់មានគិតស្រម៉ៃទេអ៊ុំ?

ខ៖ អ៊ុំធ្លាប់ស្រម៉ៃ កាលដែររៀននឹងរៀនបានតិច ពេលដែរបានទៅបួសនឹងអ៊ុំស្វាត់ស្វែងរៀននឹង កាលពី រៀនដំបូងនឹងអ៊ុំរៀននៅស្រុកណា ដល់ពេលលើកទី២អ៊ុំមករៀននៅខេត្តកំពត ដល់ពេលដែរលើកទី៣ នឹងអ៊ុំទៅរៀននៅដល់វត្តកំពុងថ្មហោស

ក៖ វត្តកំពុងថ្មនៅណាដែរអ៊ុំ?

ខ៖ នៅឯកំពង់ធំនឹង ហើយដល់ទី៤ទៀតអ៊ុំបានទៅរៀនដល់កំពង់ចាម ហើយពេលដែរប្រលងនឹងបាន ប្រលងទៅយកសញ្ញាប័ត្រនៅកំពង់ចាមនឹង

ក៖ អូ!អ៊ុំរៀបបានច្រើនកន្លែងផង?

ខ៖ នឹងហើយរួចបានមករៀននៅវត្តមហាមន្ត្រីនេះ ដល់ពេលហើយបានទៅប្រលងគ្រូដល់ពេលដែរប្រលងធ្លាក់ទៅបានមករៀននៅសាលាឯកជននឹង

ក៖ អ៊ុំប្រលងអីគេនៅឯកជននឹងអ៊ុំ?

ខ៖ ប្រលងធ្វើគ្រូបានជាប់នៅសាលាឯកជននឹង សំខាន់នឹងត្រូវមានចំនេះវិជ្ជាដើម្បីអោយជួយរឿង ជីវភាពនឹង

ក៖ ប៉ុន្តែអ៊ុំមានធ្លាប់គិតថាពីក្មេងអ៊ុំមានធ្លាប់ចង់ធ្វើអីគេលក្ខណៈថាដូចជាដុកទ័រចឹងអ៊ុំ?

ខ៖ មិនបានគិតទេ

ក៖ អូ!អ៊ុំមិនធ្លាប់គិតផងហោសអ៊ុំ?

ខ៖ គិតថាអោយតែបានចេះនឹងខ្ញុំប្រាថ្នាធ្វើជាគ្រូ

ក៖ អ៊ុំចង់ធ្វើជាគ្រូហោសអ៊ុំ?

ខ៖ នឹងហើយចង់ធ្វើជាគ្រូបង្រៀននឹង

ក៖ ប៉ុន្តែអ៊ុំបានធ្វើជាគ្រូដូចអ្វីដែរអ៊ុំប្រាថ្នាហើយ?

ខ៖ វាបានធ្វើដូចអ្វីដែរគិតមែន

ក៖ ចុះបើចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយរបស់អ៊ុំ
តើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអោយគាត់ខំ រៀនសូត្រ
រឺអោយគាត់ខំធ្វើជាពលរដ្ឋដល់ល្អមួយនៅក្នុងសង្គម លក្ខណះចូលព្រះវិហារដើម្បី
អោយពួកគាត់មានសុភមង្គលអីចឹងអ៊ុំ អ៊ុំគិតថាចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខ៖ យោបល់ខ្ញុំគឺចង់ផ្ដែផ្ដាំទៅប្អូនកូនចៅ

ក៖ ខាងកូនចៅហោសអ៊ុំ?

ខ៖ អោយកូនចៅទាំងអស់អោយភ្ញាក់រលឹកឡើងថាដើម្បីកំណើតរបស់យើងជាកូនរបស់ព្រះ

ក៖ ត្រូវហើយអ៊ុំ

ខ៖ ហើយកាលណាពេលដែរយើងដឹងថាយើងជាកូនរបស់ព្រះហើយ
យើងត្រូវធ្វើយ៉ាងណាអោយមានសិល្ប៍ នឹងដឹងច្បាប់បានល្អ នៅក្នុងខ្លួនកំអោយធ្លាក់ចុះ
កសាងជីវិតរបស់យើងទៅតាមដំណ្ណឹងរបស់ព្រះ

ក៖ បាទល្អហើយអ៊ុំ ត្រូវទៀត?

ខ៖ ធ្វើយ៉ាងម៉េចក៏ដោយ អោយតែយើងអាចទៅរស់នៅជាមួយព្រះវរបិត្រាវិញ

ក៖ ចឹងមានអីចង់ផ្ដែផ្ដាំអីផ្សេងទៀតអត់អ៊ុំ?

ខ៖ ដូចជាអស់ហើយនឹង

ក៖  ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិនឹង ហើយការសំភាសន៍របស់អ៊ុំទាំងអស់នឹងខ្ញុំដាក់ទៅក្នុងវេបសាយរស់សាលាដែរមានឈ្មោះBYU ហើយនឹងគេបានរក្សាជាអ៊ុំ?

ខ៖  បាទក្មួយអរគុណដូចគ្នា នឹងមួយទៀតបានថ្នាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាល នឹងអោយអ្នករាល់គ្នានឹងអោយកាន់តែលក្ខណះទុអោយ

ក៖  ចឹងអរគុណច្រៀនអ៊ុំ៕